ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកំពង់ចាម

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការគ្រប់គ្រងការបង្ហោះដ្រូន( Drone) គ្រប់ប្រភេទក្នុងភូមិសាស្ត្រខេត្តកំពង់ចាម

រដ្ឋបាលខេត្តកំពង់ចាម សូមជម្រាបជូនដំណឹងដល់សាធារណជន មេត្តាជ្រាបថា៖ ៖ ក្នុងគោលបំណងលើកកម្ពស់ការគ្រប់គ្រង និងថែរក្សាសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ក្នុងកាលៈទេសៈដែលប្រទេសជាតិ ត្រូវបានប្រទេសថៃរំលោភបំពានមកលើអធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា រដ្ឋបាលខេត្តកំពង់ចាម សូមធ្វើការណែនាំដូចខាងក្រោម៖

១- ហាមដាច់ខាតការបង្ហោះដ្រូន (Drone) គ្រប់ប្រភេទក្នុងភូមិសាស្ត្រខេត្តកំពង់ចាម ចាប់ពីពេលនេះតទៅ។

២- ក្នុងករណីប្រជាពលរដ្ឋក្នុងមូលដ្ឋាន ប្រទះឃើញមានការបង្ហោះដ្រូន គ្រប់ប្រភេទ សូមរាយការណ៍ជាបន្ទាន់មកសមត្ថកិច្ច ដើម្បីចាត់វិធានការឱ្យបានទាន់ពេលវេលា។

៣- សូមបងប្អូនប្រជាពលរដ្ឋ កុំបង្ហោះ ឬផ្សព្វផ្សាយរូបភាពនានាលើបណ្ដាញសង្គមពាក់ព័ន្ធការចល័តកងកំលាំងយោធា ឬទីតាំងយោធានានា។

៤- សូមបងប្អូនប្រជាពលរដ្ឋដែលមានដ្រូនទាំងអស់ ត្រូវមកចុះឈ្មោះប្រើប្រាស់ដ្រូន នៅតាមរដ្ឋបាលក្រុង-ស្រុកដែលខ្លួនរស់នៅ។

ទទួលបានសេចក្ដីជូនដំណឹងនេះ និងក្នុង «**ស្មារតីរួបរួម ការពារជាតិ មាតុភូមិរបស់យើង**» រដ្ឋបាលខេត្តកំពង់ចាម សង្ឃឹម និងជឿជាក់ថាបងប្អូនប្រជាពលរដ្ឋទាំងអស់នឹងចូលរួមសហការប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់៕

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
កំពង់ចាម ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥

**រដ្ឋបាលខេត្តកំពង់ចាម**